Futures GROUP
Insight for a Better World

### ប្រធានគម្រោង HIPA នៃអង្គការ FUTURES GROUP

### សូមគោរពជូន

### លោកវេជ្ជបណ្ឌិត ឡូ វាសនាគីរី ប្រធាននាយកដ្ឋានផែនការ និងព័ត៌មានសុខាភិបាល

**កម្មវត្ថុៈ** ស្នើសុំអនុញ្ញាត ធ្វើការ Upload ឧបករណ៍ថ្មីសម្រាប់កំណត់រយៈពេលបញ្ចូល និងកែប្រែទិន្នន័យសុខាភិបាល ប្រចាំខែ ទៅក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាលតាមគេហទំព័រ ដើម្បីប្រើប្រាស់ទៅថ្ងៃអនាគត។

តបតាមកម្មវត្ថុខាងលើ នាងខ្ញុំសូមជម្រាបជូន លោកវេជ្ជបណ្ឌិត ជ្រាបថា យោងតាមការពិភាក្សាគ្នារវាងមន្ត្រីការិយាល័យប្រព័ន្ធព័ត៌មានសុខាភិបាល និងបុគ្គលិកអង្គការ FUTURES GROUP អំពីការកំណត់រយៈពេលក្នុងការបញ្ចូល និងកែប្រែទិន្នន័យប្រព័ន្ធព័ត៌មានប្រចាំខែកន្លងមក ការពិភាក្សាបានឯកភាព លើចំណុចដែលបានរៀបរាប់ខាងក្រោមនេះៈ

១. អនុញ្ញាតឱ្យមូលដ្ឋានសុខាភិបាល ឬការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ បញ្ចូលទិន្នន័យប្រចាំខែ រហូតដល់ថ្ងៃទី ១៥ នៃខែបន្ទាប់ (ឧទាហរណ៍ៈ ការបញ្ចូលទិន្នន័យខែមករាអាចធ្វើបានរហូតដល់ថ្ងៃទី ១៥ ខែកុម្ភៈ)។

២. ចាប់ពីថ្ងៃទី ១៦ នៃខែបន្ទាប់ រហូតដល់ថ្ងៃដាច់ខែ ក្នុងករណីដែលការសុំកែប្រែទិន្នន័យមានលក្ខណៈត្រឹមត្រូវតាមបច្ចេកទេស និងមានការអនុញ្ញាតពីការិយាល័យប្រព័ន្ធព័ត៌មានសុខាភិបាល មូលដ្ឋានសុខាភិបាល ឬការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ អាចកែប្រែទិន្នន័យខែមុនបានដោយខ្លួនឯង (ឧទាហរណ៍ៈ ការកែប្រែទិន្នន័យខែមករា អាចធ្វើបានរហូតដល់ថ្ងៃទី ២៨ ខែកុម្ភៈ)។

៣. ចាប់ពីថ្ងៃកំណត់ចុងក្រោយ (ឧទាហរណ៍ៈ ថ្ងៃទី ២៨ ខែកុម្ភៈ), រាល់ការកែប្រែទិន្នន័យ អាចធ្វើបានតែនៅថ្នាក់ជាតិ និងតែក្នុងករណីដែលលិខិតស្នើសុំកែប្រែមានលក្ខណៈត្រឹមត្រូវតាមបច្ចេកទេស និងមានការអនុញ្ញាតពីការិយាល័យប្រព័ន្ធព័ត៌មានសុខាភិបាល (ឧទាហរណ៍ៈ សម្រាប់ខែមករា ការកែប្រែនេះមិនត្រូវលើសពីថ្ងៃទី ៣១ ខែមិនាឡើយ)។

ទាំងអស់នេះ ធ្វើឡើងក្នុងគោលបំណង ធ្វើយ៉ាងណាឱ្យទិន្នន័យនៃប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាល មានលក្ខណៈសុក្រឹត អាចទទួលយកបាន សម្រាប់ការប្រើប្រាស់ក្នុងការអភិវឌ្ឍប្រទេសជាតិយើង។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកវេជ្ជបណ្ឌិត មេត្តាជួយសម្រួល និងអនុញ្ញាតដោយអនុគ្រោះ។

សូមលោកវេជ្ជបណ្ឌិត ទទួលនូវការគោរពរាប់អាន អំពីនាងខ្ញុំ។

ភ្នំពេញ ថ្ងៃទី ៦ ខែមិនា ឆ្នាំ២០១៥

**ប្រធានគម្រោង HIPA**

**វេជ្ជ. ឌីនើគើ ទេនើខាមត៍**

30/03/2015


Floor 2, # 49, Sihanouk Blvd (59)
Sangkat Chaktomouk, Khan Daun Penh
Phnom Penh, Cambodia
TEL 077.627.280
www.futuresgroup.com